អង្គការសហការ
គ្រប់ជ្រុងជ្រោយ
ដើម្បីកម្ពុជា

# ឱកាសការងារ

## តួនាទី៖ មន្ត្រីអប់រំមូលដ្ឋាន – ព្រៅ និងកាវ៉ែត

អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា (អង្គការសហការ - ICC) គឺជាអង្គការគ្រីស្ទបរិស័ទក្នុងស្រុក ដែលផ្តោតលើការអភិវឌ្ឍ និងពង្រឹងភាពអង់អាចដល់សហគមន៍ នៅប្រទេសកម្ពុជា។

**គម្រោងអប់រំផ្សារភ្ជាប់នឹងវប្បធម៌ដើម្បីភាពធន់នឹងអាកាសធាតុនៅក្នុងសហគមន៍ជនជាតិដើមភាគតិច** (CRE4CRI / KHK009, ២០២៦–២០២៩) នៅខេត្តរតនគិរី។ គម្រោងនេះមានគោលបំណងលើកកម្ពស់ការអប់រំពហុភាសាផ្អែកលើភាសាកំណើតប្រកបដោយបរិយាបន្ន (MT-MLE) សម្រាប់កុមារជនជាតិដើមភាគតិចរួមមាន ទំពួន គ្រឹង ព្រៅ ចារ៉ាយ និង កាវ៉ែត នៅថ្នាក់មត្តេយ្យសិក្សា បឋមសិក្សា និងថ្នាក់អក្ខរកម្មផ្អែកលើសហគមន៍។

**គម្រោង៖** សូមប្រកាសជ្រើសរើសបេក្ខជនដែលមានសមត្ថភាព ដើម្បីធ្វើការជា **មន្ត្រីអប់រំមូលដ្ឋាន-ព្រៅ និងកាវ៉ែត ចំនួន ០១ នាក់។**

**ប្រាក់បៀវត្សរ៍៖** ចន្លោះពី ៣៥០ ទៅ ៣៨០ ដុល្លារក្នុងមួយខែ បូករួមនឹងអត្ថប្រយោជន៍ផ្សេងៗទៀត។

### មន្ត្រីគម្រោង

| | | |
|---|---|---|
| មុខតំណែង | : | មន្ត្រីអប់រំមូលដ្ឋាន - ភាសាព្រៅ និងកាវ៉ែត |
| វិស័យការងារ | : | អប់រំពហុភាសាសម្រាប់ជនជាតិដើមភាគតិចនៅកម្ពុជា |
| ជំនាញរំពឹងទុក | : | ស្ទាត់ជំនាញភាសាព្រៅ ឬកាវ៉ែត និងភាសាខ្មែរ ជំនាញ សម្របសម្រួល ទំនាក់ទំនង បណ្តុះបណ្តាល ការរៀបចំផែនការ របាយការណ៍ ជំនាញកុំព្យូទ័រមូលដ្ឋាន និងកម្មវិធីប្រមូលទិន្នន័យតាមទូរស័ព្ទ |
| មូលដ្ឋានទីតាំង | : | ខេត្តរតនគិរី |
| តំបន់ការងារគោលដៅ | : | ជាមួយនឹងការធ្វើដំណើរញឹកញាប់ និងការស្នាក់នៅក្នុងសហគមន៍ជនជាតិដើមភាគតិចជនបទ |
| កិច្ចសន្យាការងារ | : | មានថិរវេលាមិនកំណត់ |
| របាយការណ៍ឱ្យទៅ | : | អ្នកសម្របសម្រួលអប់រំបរិយាបន្ន |

### គោលបំណងការងារ

មន្ត្រីអប់រំមូលដ្ឋាន – ព្រៅ និងកាវ៉ែត ទទួលបន្ទុកលើការអនុវត្តប្រចាំថ្ងៃ ការសម្របសម្រួល និងការតាមដានត្រួតពិនិត្យនៅកម្រិតមូលដ្ឋាន នូវសកម្មភាព MT-MLE របស់គម្រោង នៅក្នុងភូមិគោលដៅដែលនិយាយភាសាព្រៅ និងកាវ៉ែត ដើម្បីធានាថាកុមារជនជាតិដើមភាគតិចទទួលបានការអប់រំប្រកបដោយគុណភាព និងសមស្របនឹងវប្បធម៌ គ្រូបង្រៀនអនុវត្តវិធីសាស្ត្របង្រៀន MT-MLE ដែលបានកែលម្អ សិស្សដែលមានការលំបាកក្នុងការរៀន និងកុមារពិការទទួលបានការគាំទ្របន្ថែម ព្រមទាំងគំនិតអំពីភាពធន់នឹងអាកាសធាតុសមស្របតាមអាយុ ត្រូវបានណែនាំចូលក្នុងថ្នាក់រៀន។

**ទំនួលខុសត្រូវសំខាន់ៗ៖**

- សម្របសម្រួល និងគាំទ្រការផ្តល់ថ្នាក់មត្តេយ្យ បឋមសិក្សា និងថ្នាក់អក្ខរកម្មនៅតាមសហគមន៍។
- ធ្វើដំណើរទៅសាលារៀន និងថ្នាក់រៀនជាប្រចាំ ដើម្បីសង្កេតការបង្រៀន ផ្តល់ការណែនាំ ដល់គ្រូបង្រៀនអក្ខរកម្មនៅតាមសហគមន៍។
- គាំទ្រការផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្រៀនក្នុងពេលបំពេញការងារ និងផ្ទៀងផ្ទាត់ការអនុវត្តវិធីសាស្ត្រ MT-MLE នៅក្នុងថ្នាក់រៀន។
- សម្របសម្រួលការសាកល្បង ការចែកចាយ និងការប្រើប្រាស់កម្មវិធីសិក្សា សៀវភៅ និងសម្ភារៈបង្រៀន-រៀន MT-MLE ជាភាសាព្រៅ និងកាវ៉ែត។
- លើកកម្ពស់ការចុះឈ្មោះចូលរៀន ការមករៀនទៀងទាត់ និងការរក្សាសិស្សឱ្យបន្តរៀន ដោយយកចិត្តទុកដាក់ជាពិសេសលើកុមារី និងកុមារពិការ (ប្រហែល ៥%)។
- កសាងទំនាក់ទំនងការងារជាមួយនាយកសាលា គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន (SMCs) អាជ្ញាធរភូមិ និងឃុំ ឪពុកម្តាយ និងមេដឹកនាំសហគមន៍ជនជាតិដើមភាគតិច ។
- ប្រមូល ផ្ទៀងផ្ទាត់ និងរាយការណ៍ទិន្នន័យមូលដ្ឋានធៀបនឹងសូចនាករគម្រោង ដោយបំបែកតាមភេទ និងពិការភាព ព្រមទាំងចងក្រងឯកសាររឿងរ៉ាវជោគជ័យ និងមេរៀនបទពិសោធន៍។
- រៀបចំផែនការសកម្មភាព ផែនការថវិកា ភស្តុតាង និងធានាការអនុលោមតាមគោលនយោបាយការពារកុមារ/ការធានាសុវត្ថិភាព និងក្រមសីលធម៌របស់អង្គការ។

**លក្ខខណ្ឌតម្រូវ ឬលក្ខណសម្បត្តិ**

☑ បរិញ្ញាបត្រផ្នែកអប់រំ វិទ្យាសាស្ត្រសង្គម អភិវឌ្ឍន៍ជនបទ ឬវិស័យពាក់ព័ន្ធ ឬមានវិញ្ញាបនបត្របណ្តុះបណ្តាលគ្រូបង្រៀន ឬមានបទពិសោធន៍ពាក់ព័ន្ធនានា អាចត្រូវបានពិចារណា។

☑ មានបទពិសោធន៍យ៉ាងតិច ពីរ (២) ឆ្នាំ ក្នុងតួនាទីគម្រោងអប់រំនៅមូលដ្ឋាន អភិវឌ្ឍន៍សហគមន៍ ឬអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការក្នុងសហគមន៍ជនជាតិដើមភាគតិច ឬតំបន់ជនបទដាច់ស្រយាល។

☑ បទពិសោធន៍ក្នុងការអប់រំពហុភាសា( MT-MLE )ការអប់រំបរិយាបន្ន ការអប់រំកុមារតូច ឬអក្ខរកម្មក្រៅប្រព័ន្ធ។

☑ ចេះនិយាយស្ទាត់ជំនាញភាសាព្រៅ ឬកាវ៉ែត គឺជាតម្រូវការចាំបាច់ ព្រមទាំងនិយាយ និងសរសេរភាសាខ្មែរបានល្អ ហើយមានចំណេះដឹងភាសាអង់គ្លេសជាមូលដ្ឋានរឹតតែប្រសើរ។

☑ ចំណេះដឹងអំពីសិទ្ធិកុមារ សមភាពយេនឌ័រ ការបញ្ចូលជនពិការ គោលការណ៍ការពារកុមារ និងការយល់ដឹងជាមូលដ្ឋានអំពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

☑ មានជំនាញកុំព្យូទ័រមូលដ្ឋាន (Microsoft Word, Excel, អ៊ីមែល, កម្មវិធីប្រមូលទិន្នន័យតាមទូរស័ព្ទ) និងសមត្ថភាពធ្វើការដោយឯករាជ្យនៅមូលដ្ឋាន។

☑ មានសមត្ថភាពបើកបរម៉ូតូដោយសុវត្ថិភាពនៅលើផ្លូវជនបទ ព្រមទាំងមានឆន្ទៈធ្វើដំណើរញឹកញាប់ និងស្នាក់នៅពេលយប់នៅភូមិគោលដៅដាច់ស្រយាល។

☑ មានឆន្ទៈក្នុងការចុះហត្ថលេខា និងអនុលោមតាមគោលនយោបាយការពារកុមារ/ការធានាសុវត្ថិភាព និងក្រមសីលធម៌របស់អង្គការ ព្រមទាំងទទួលការត្រួតពិនិត្យប្រវត្តិរូបតាមតម្រូវការ។

## សមភាព និងការការពារកុមារ

អង្គការយើងផ្តល់ឱកាសការងារស្មើភាពគ្នា និងលើកទឹកចិត្តយ៉ាងខ្លាំងដល់បេក្ខជនស្ត្រី បេក្ខជនជនជាតិដើមភាគតិច និងបេក្ខជនជនមានពិការភាព ឱ្យដាក់ពាក្យ។ បេក្ខជនដែលចេះនិយាយភាសាកាវ៉ែត និងព្រៅត្រូវបានផ្តល់អាទិភាព។ អង្គការប្រកាន់ខ្ជាប់នូវគោលនយោបាយការកិច្ចពារសុវត្ថិភាពកុមារ។ បេក្ខជនដែលត្រូវបានជ្រើសរើសត្រូវឆ្លងកាត់ការត្រួតពិនិត្យប្រវត្តិរូប និងចុះហត្ថលេខាលើក្រមសីលធម៌របស់អង្គការ។

## ការដាក់ពាក្យស្នើសុំ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមដាក់ជូនឯកសារដូចខាងក្រោម៖

- លិខិតដាក់ពាក្យសុំបម្រើការងារ (Cover Letter)
- ប្រវត្តិរូបសង្ខេប (CV) ដែលមានឈ្មោះអ្នកធានាចំនួន ០២រូប
- ច្បាប់ចម្លងសញ្ញាបត្រ វិញ្ញាបនបត្រ អត្តសញ្ញាណប័ណ្ណ បើមានប័ណ្ណបើកបរកាន់តែប្រសើរ

ទម្រង់នៃពាក្យស្នើសុំអាចទាញយកពីគេហទំព័ររបស់អង្គការសហការ៖ https://icc.org.kh/opportunities.php ហើយបេក្ខជនត្រូវផ្ញើឯកសារទន់ (soft copy) ដោយបំលែងជា PDF ទៅកាន់អ៊ីម៉ែលប្រធានគម្រោង៖ rtk.pm@icc.org.kh និងចម្លង ( CC )៖ mle.pc@icc.org.kh, rtk.meal@icc.org.kh ។

**បញ្ជាក់៖** មានតែបេក្ខជនដែលជាប់ក្នុងបញ្ជីសម្រាំងប៉ុណ្ណោះ នឹងធ្វើការទាក់ទងតាមទូរសព្ទ ដើម្បីធ្វើការណាត់ សម្ភាសន៍។ អង្គការសហការ (ICC) មានការប្តេជ្ញាក្នុងការការពារកុមារ និង ក្នុងការការពារពីការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ។ ម្លោះហើយ ការផ្តល់ការងារ គឺតម្រូវឱ្យមានការត្រួតពិនិត្យពីប្រវត្តិរូបរបស់បេក្ខជន និង កំណត់ត្រាផ្សេងៗរបស់បេក្ខជន ដែលធ្លាប់ស្នាក់នៅ ឬបម្រើការងារ។

**<u>កាលបរិច្ឆេទឈប់ទទួលពាក្យ៖</u> ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៦ វេលាម៉ោង៥:០០ល្ងាច**

## ព័ត៌មានទំនាក់ទំនង៖

ការិយាល័យអង្គការសហការ (ICC) ស្ថិតនៅភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។
លេខទំនាក់ទំនង៖ 097 72 23 886 / 097 21 61 530